# ការសម្ភាសន៍របស់អ្នកមីង ខៀវ គឹមសឿន

កៈ អ្នកសំភាសន៍ឈ្មោះ គង់ ចាន់ណាក់ ខៈ អ្នកដែលត្រូវបានគេសំភាសន៍ឈ្មោះ សុខ សោ

<u>ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ សុខ សោ</u>

សង្ខេបៈ អ្នកមីង ខៀវ គឹមសឿង គាត់មានអាយុហុកសិបបួនឆ្នាំ ហើយគាត់បានកើតនៅភូមិពោន ឃុំមង់រៀង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ គាត់មានបងប្អូនចំនួនប្រាំមួយនាក់ ហើយគាត់ជាកូនទីបីនៅក្នុងក្រុមគ្រួសារ។ បងប្អូនរបស់គាត់ពីរនាក់បានស្លាប់នៅសល់តែបួននាក់ទេ បងប្អូនរបស់គាត់ម្នាយស្លាប់ដោយសារពួកពលពតយកទៅសំលាប់ចោល ហើយម្នាក់ទៀតគាត់ស្លាប់ដោយសារជម្ងឺ។ ហើយគាត់បានរៀបការនៅក្នុងឆ្នាំមួយពាន់ប្រាំបួនរយប៉ែតសិបមួយ នៅពេលដែលគាត់មានអាយុម្ភៃប្រាំឆ្នាំ ហើយគាត់មានកូនស្រីតែម្នាក់ទេ។ នៅក្នុងសម័យសង្គ្រាមពលពតគេបានជំលៀសគាត់ទៅនៅភ្នំពេញហើយធ្វើការនៅក្នុងរោចចក្រកៅស៊ូនៅភ្នំពេញ។ នៅក្នុងជីវិតរបស់គាត់មានការលំបាកច្រើនតែគាត់មានការតស៊ូច្រើនណាស់។ធ្វើឡើងនៅភូមិពោន ឃុំមង់រៀង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ធ្វើឡើងនៅថ្ងៃទី២៨ ខែ០៦ ឆ្នាំ២០១៨។

កៈ ហើយអញ្ចឹង ជំរាបសួរអ្នកមីង ខ្ញុំឈ្មោះ គង់ ចាន់ណាក់ ហើយខ្ញុំមកពីគម្រោងជីវប្រវត្តិផ្ទាល់របស់ប្រជាជនកម្ពុជាដែលធ្វើឡើងដោយសាកលវិទ្យាល័យមួយនៅសហរដ្ឋអាមេរិចដែលមានឈ្មោះថា សាកលវិទ្យាល័យ ប៊ី វ៉ាយ យូ ដោយសារសាកលវិទ្យាល័យមានគម្រោងដើម្បីជួយថៃរក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរទុក ដើម្បីទុកអោយកូនចៅជំនាន់ក្រោយពួកគាត់អាចរៀនហើយនឹងស្គាល់ពីប្រវត្តិរបស់ជីដូនជីតាហើយនឹងឪពុកម្តាយ។ ហើយសំរាប់ការសម្ភាសន៍នឹងយើងធ្វើនៅភូមិពោន ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ ហើយយើងធ្វើការសម្ភាសន៍នឹងនៅថ្ងៃទី២៨ ខែ០៦ ឆ្នាំ២០១៨។ ហើយអញ្ចឹងសំរាប់ការសម្ភាសន៍មួយនឹង យើងនឹងថតជាសំលេង ហើយនឹងថតរូបភាពដើម្បីយើងអាចផ្ញើរទៅកាន់សាកលវិទ្យាល័យដើម្បីពួកគាត់អាចយកសំលេងហើយនឹងរូបភាពយើងដាក់លើវេបសាយរបស់សាកលវិទ្យាល័យ។ ហើយអញ្ចឹងតើអ្នកមីងយល់ព្រមដើម្បីយើងយកសំលេងហើយនឹងរូបភាពរបស់អ្នកមីងដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យបានទេ អ្នកមីង?

ខៈ បាន។

កៈ អញ្ចឹង អរគុណច្រើនហើយអ្នកមីងដែលបានអនុញ្ញាតិអោយខ្ញុំយកសំលេងហើយនឹងរូបភាពរបស់អ្នកមីងដើម្បីដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យ។ ហើយអញ្ចឹងដំបូងសុំសួរដល់អ្នកមីងថា តើអ្នកមីងមានឈ្មោះអ្វីដែរ អ្នកមីង?

ខ៖ ខ្ញុំឈ្មោះ ខៀវ គឹមសឿន។

ក៖ ខៀវ គឹមសឿន! ហើយអញ្ចឹង តើអ្នកមីងមានឈ្មោះហៅក្រៅទេ អ្នកមីង?

ខ៖ អត់មានផង។

ក៖ អត់មានទេ! ហើយអញ្ចឹង កាលដែលអ្នកមីងនៅក្មេងៗ តើគេហៅឈ្មោះរបស់អ្នកមីងថាម៉េចដែរ អ្នកមីង?

ខ៖ គេហៅឈ្មោះ គឹមសឿននឹង។

ក៖ គឹមសឿន! អត់មានឈ្មោះហៅក្រៅអី រហ័សនាមអី អត់មានទេ?

ខ៖ អត់មានទេ។

ក៖ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ សព្វថ្ងៃនេះខ្ញុំមានអាយុហុកសិបបួនឆ្នាំហើយ។

ក៖ អ្នកមីងមានអាយុហុកសិបបួនឆ្នាំហើយ! ហើយអញ្ចឹង តើអ្នកមីងមាននៅចាំថា អ្នកមីងបានកើតនៅក្នុងឆ្នាំណាទេ អ្នកមីង?

ខ៖ ខ្ញុំបានកើតក្នុងឆ្នាំមួយពាន់ប្រាំបួនរយសែសិបប្រាំពីរ។

ក៖ អូ! អ្នកមីងបានកើតក្នុងឆ្នាំមួយពាន់ប្រាំបួនរយសែសិបប្រាំពីរ។ ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងកើតឆ្នាំខ្មែរដូចជា ឆ្នាំជូត ឆ្លូវ ខាល ថោះ រោង ម្សាញ់នឹង អ្នកមីងបានកើតក្នុងឆ្នាំណាដែរ អ្នកមីង?

ខ៖ ខ្ញុំកើតឆ្នាំមមែ។

ក៖ អូ! អ្នកមីងកើតឆ្នាមមែ។ ហើយអញ្ចឹង តើអ្នកមីងបានកើតនៅក្នុងខេត្តណាដែរ អ្នកមីង?

ខ៖ ខ្ញុំកើតនៅខេត្តនឹង ភូមិនឹង ស្រុកនឹងតែម្តង។

ក៖ ហើយអញ្ចឹង តើអ្នកមីងអាចជួយរៀបរាប់ឈ្មោះភូមិ ឃុំ ស្រុក ខេត្ត បានទេ អ្នកមីង?

ខ៖ ភូមិពោន ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីង តើអ្នកមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរ អ្នកមីង?

ខ៖ ខ្ញុំមានបងប្អូនចំនួនប្រាំមួយនាក់។

ក៖ អូ! អ្នកមីងមានបងប្អូនចំនួនប្រាំមួយនាក់។ ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងជាកូនទីប៉ុន្មាននៅក្នុងក្រុមគ្រួសារដែរ អ្នកមីង?

ខ៖ ខ្ញុំជាកូនទីបីនៅក្នុងក្រុមគ្រួសារ។

ក៖ អ្នកមីងជាកូនទីបី! ហើយអញ្ចឹងសំរាប់បងប្អូនរបស់អ្នកមីងទាំងប្រាំមួយនាក់នឹង តើមានស្រីប៉ុន្មាននាក់ ហើយប្រុសប៉ុន្មាននាក់ដែរ អ្នកមីង?

ខ៖ ខ្ញុំមានបងប្អូនស្រីបីនាក់ ហើយប្រុសបីនាក់។

ក៖ ហើយអញ្ចឹង តើអ្នកមីងអាចជួយរៀបរាប់ឈ្មោះរបស់បងប្អូនរបស់អ្នកមីងទាំងប្រាំមួយនាក់នឹង បានទេ អ្នកមីង?

ខ៖ បងបង្អស់ឈ្មោះខៀវ ចន ហើយទីពីរឈ្មោះខៀវ ឆាន ហើយទីបីខ្ញុំខៀវ គឹមសឿន ហើយទីបួនឈ្មោះខៀវ គឹមហាន ហើយទីប្រាំឈ្មោះខៀវ គឹមហឿន ហើយទីប្រាំមួយឈ្មោះខៀវ សុផៃ។

ក៖ អរគុណច្រើនអ្នកមីង!
ហើយអញ្ចឹងតើអ្នកមីងមានចងចាំសាច់រឿងអំពីបងប្អូនអ្នកមីងពេលពួកគាត់នៅក្មេងទេ អ្នកមីង?

ខ៖ ខ្ញុំអត់មានចងចាំពីរឿងនៅពីក្មេងផង។

ក៖ ហើយអញ្ចឹង កាលដែលអ្នកមីងនៅក្មេងៗ
តើអ្នកមីងចូលចិត្តធ្វើអ្វីខ្លះជាមួយបងប្អូនរបស់អ្នកមីង?

ខ៖ គ្មានធ្វើអីទេ ខ្ញុំពរតែប្អូនមើលតែប្អូនកាលនៅតូចៗ ពេលដែលម៉ែឪទៅធ្វើស្រែចំការ។

ក៖ អញ្ចឹងយើងនៅផ្ទះមើលប្អូន។ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ
តើបងប្អូនរបស់អ្នកមីងទាំងអស់គាត់រស់នៅកន្លែងណាខ្លះដែរ អ្នកមីង?

ខ៖ ស្លាប់អស់ពីនាក់ហើយ នៅសល់តែបួននាក់ទេ ហើយនៅក្នុងភូមិនឹងបីនាក់
ហើយនឹងនៅភ្នំពេញម្នាក់។

ក៖ អូ! នៅភ្នំពេញម្នាក់! ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ តើបងប្អូនរបស់អ្នកមីងទាំងបួននាក់នឹង ពួកគាត់ប្រកបមុខរបរអ្វីដែរ អ្នកមីង?

ខ៖ ធ្វើស្រែមួយ ហើយធ្វើជាប៉ូលីស។

ក៖ អូ! បងប្អូនអ្នកមីងដែលនៅភ្នំពេញនឹងគាត់ធ្វើជាប៉ូលីលមែន អ្នកមីង?

ខ៖ អត់ទេ គាត់នៅនឹងភូមិយើងនឹងតើ។

ក៖ ហើយអញ្ចឹង តើបងប្អូនរបស់អ្នកមីងដែលគាត់នៅភ្នំពេញនឹងគាត់រកស៊ីអ្វីដែរ អ្នកមីង?

ខ៖ កាត់ដេរ រកស៊ីតិចតួច។

កៈ អូ! កាត់ដេរ ហើយរកស៊ីតិចតួចនៅនឹងផ្ទះ។ ហើយអញ្ចឹង បងប្អូនរបស់អ្នកមីងទាំងពីរនាក់ដែលបានស្លាប់នឹង តើពួកគាត់បានស្លាប់ដោយសារមូលហេតុអ្វីដែរ អ្នកមីង?

ខៈ បងមួយបានស្លាប់ដោយសារគេយកទៅវាយចោល ហើយបងមួយទៀតគាត់ស្លាប់ដោយសារឈឺ។

កៈ បងគេបង្អស់គាត់ស្លាប់ដោយសារឈឺ។ ហើយអញ្ចឹង តើគាត់បានស្លាប់ប្រហែលជាឆ្នាំណាដែរ បងគេបង្អស់នឹង?

ខៈ គាត់ទើបតែស្លាប់បានមួយឆ្នាំទេ។

កៈ អូ! គាត់ទើបស្លាប់បានមួយឆ្នាំទេ អ្នកមីង! អញ្ចឹងគាត់ស្លាប់ឆ្នាំទៅ។ ហើយអញ្ចឹង មួយទៀតគេយកទៅវាយចោលជំនាន់ពលពត មែនទេអ្នកមីង?

ខៈ ហ្នឹងហើយ! មួយទៀតគេយកទៅវាយចោលជំនាន់ពលពត។

កៈ ហើយអញ្ចឹង គេយកគាត់ទៅវាយចោលប្រហែលឆ្នាំណាដែរ អ្នកមីងមាននៅចាំទេ?

ខៈ អត់ដឹងផង អត់ចាំទេ។

កៈ ហើយអញ្ចឹង តើម្ដាយរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខៈ ម្ដាយរបស់ខ្ញុំគាត់ឈ្មោះ អេង គី។

កៈ អេង គី! ហើយអញ្ចឹង តើម្ដាយរបស់អ្នកមីងគាត់បានកើតនៅក្នុងឆ្នាំណា អ្នកមីងដឹងទេ?

ខៈ អត់ដឹងគាត់កើតឆ្នាំណាទេ។

កៈ ហើយអញ្ចឹង តើម្ដាយរបស់អ្នកមីងគាត់កើតឆ្នាំខ្មែរឆ្នាំអ្វី អ្នកមីងចាំទេ?

ខៈ ម្ដាយរបស់ខ្ញុំគាត់បានកើតឆ្នាំឆ្លូវ។

កៈ ហើយអញ្ចឹង តើម្ដាយរបស់អ្នកមីងគាត់បានកើតនៅកន្លែងណាដែរ អ្នកមីង?

ខៈ ម្ដាយរបស់ខ្ញុំគាត់បានកើតនៅខេត្តព្រៃវែង។

កៈ អូ! អញ្ចឹងម្ដាយរបស់អ្នកមីងគាត់បានកើតនៅខេត្តព្រៃវែង។ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ ម្ដាយរបស់អ្នកមីងគាត់បានស្លាប់ហើយមែនទេ អ្នកមីង?

ខៈ ហ្នឹងហើយ! គាត់ស្លាប់បាត់ហើយ។

កៈ ហើយអញ្ចឹង តើម្ដាយរបស់អ្នកមីងគាត់បានស្លាប់ឆ្នាំណា អ្នកមីងមាននៅចាំទេ?

ខ៖ ម្តាយរបស់ខ្ញុំគាត់បានស្លាប់បីឆ្នាំហើយ។

ក៖ អញ្ចឹងមានន័យថាគាត់បានស្លាប់បីឆ្នាំហើយ។ ហើយអញ្ចឹង
ពេលដែលម្តាយរបស់អ្នកមីងគាត់បានស្លាប់នឹង តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ ពេលម្តាយរបស់ខ្ញុំគាត់ស្លាប់ ខ្ញុំមានអាយុហុកសិបពីរឆ្នាំ។

ក៖ អ្នកមីងអាយុហុកសិបពីរឆ្នាំ! ហើយអញ្ចឹងពេលដែលម្តាយរបស់អ្នកមីងគាត់នៅរស់
តើគាត់ប្រកបមុខរបរអ្វីដែរ អ្នកមីង?

ខ៖ គាត់អត់មានរបរអីផង កូនចៅរកស៊ីចិញ្ចឹមគាត់។

ក៖ អូ! គាត់នៅតែផ្ទះ! ហើយអញ្ចឹង ម្តាយរបស់អ្នកមីងគាត់ជាមនុស្សបែបណាដែរ ចរិតរបស់គាត់?

ខ៖ ម្តាយរបស់ខ្ញុំគាត់ស្លូតបូតទេ គាត់អត់មានចរិតម៉េចទេ គាត់ស្លូតបូតហើយជួយដល់គេណាស់។

ក៖ ហើយអញ្ចឹង សំរាប់ឪពុករបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំគាត់ឈ្មោះ ខៀវ ជិន។

ក៖ ខៀវ ជិន! ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ តើឪពុករបស់អ្នកមីងគាត់មានអាយុប៉ុន្មានឆ្នាំហើយ
អ្នកមីង?

ខ៖ មិនដឹងអាយុប៉ុន្មានទេ គាត់អាយុប៉ែតជាង កៅជាងក៏មិនដឹង។

ក៖ ហើយអញ្ចឹង ឪពុករបស់អ្នកមីងគាត់បានស្លាប់ហើយ ឬមួយគាត់នៅរស់ទេ អ្នកមីង?

ខ៖ គាត់បានស្លាប់ហើយ គាត់ស្លាប់យូរហើយ។

ក៖ អូ! គាត់បានស្លាប់យូរហើយ។ ហើយអញ្ចឹង តើឪពុករបស់អ្នកមីងគាត់បានកើតនៅពេលណា
អ្នកមីងមាននៅចាំទេ?

ខ៖ អត់ដឹង អត់ចាំទេ។

ក៖ ហើយអញ្ចឹង សំរាប់ឪពុករបស់អ្នកមីងគាត់បានកើតឆ្នាំខ្មែរឆ្នាំអ្វីដែរ អ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំគាត់បានកើតឆ្នាំរោង។

ក៖ ហើយអញ្ចឹង កាលដែលឪពុករបស់អ្នកមីងបានកើតនឹង តើគាត់បានកើតនៅកន្លែងណាដែរ
អ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំគាត់បានកើតនៅខេត្តស្វាយរៀង។

កៈ អូ! គាត់បានកើតនៅខេត្តស្វាយរៀង។ ហើយអញ្ចឹង
តើឪពុករបស់អ្នកមីងគាត់បានស្លាប់ប្រហែលប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខៈ គាត់ស្លាប់បានម្ភៃ សាមសិបឆ្នាំជាងហើយដឹង។

កៈ ហើយអញ្ចឹង ពេលដែលឪពុករបស់អ្នកមីងបានស្លាប់នឹង តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខៈ ពេលដែលឪពុកខ្ញុំស្លាប់នឹង ខ្ញុំអាយុម្ភៃជាង ឬសាមជាងហើយ ខ្ញុំភ្លេចដែរ អត់ចាំផង កាលនឹងខ្ញុំមានកូនមួយហើយ អាយុសាមហើយ។

កៈ ហើយអញ្ចឹង កាលដែលឪពុករបស់អ្នកមីងនៅរស់ តើគាត់ប្រកបមុខរបរអ្វីដែរ អ្នកមីង?

ខៈ គាត់រកស៊ីរត់រ៉ឺម៉ក ហើយនឹងធ្វើការងារអោយបារាំង។

កៈ ហើយអញ្ចឹង តើគាត់ធ្វើការអីគេដែរ អ្នកមីង?

ខៈ ធ្វើការរោងចក្រចំការកៅស៊ូយើងនឹង។

កៈ អូ! រោងចក្រចំការកៅស៊ូយើងនឹង នៅឃុំជប់នឹងហ៎!

ខៈ ហ្នឹងហើយ!

កៈ តែធ្វើការអោយបារាំង។ ហើយអញ្ចឹង ឪពុករបស់អ្នកមីងគាត់ជាមនុស្សបែបណាដែរ សំរាប់ចរិតរបស់គាត់ អ្នកមីង?

ខៈ ឪពុករបស់ខ្ញុំគាត់ស្លូតបូតទេ មិនចេះមានកនឹងគេទេ។

កៈ ហើយអញ្ចឹង តើអ្នកមីងធ្លាប់មានអនុស្សាវរីយ៍អ្វីល្អៗជាមួយឪពុកម្តាយរបស់អ្នកមីងទេ?

ខៈ ធ្លាប់មានល្អជាមួយគាត់ គាត់ជាអាណាព្យាបាលយើងគាត់ល្អជាមួយយើង
ហើយយើងល្អជាមួយគាត់។

កៈ ហើយអញ្ចឹង
សំរាប់ឪពុកម្តាយរបស់អ្នកមីងគាត់ធ្លាប់ប្រាប់អ្នកមីងពីជីវិតរបស់គាត់កាលដែលគាត់នៅក្មេងៗទេ អ្នកមីង?

ខៈ ជីវិតគាត់ពិបាកដែរ គាត់រកស៊ី គាត់វែកកូនចៅមករស់នៅនឹងភូមិយើងនឹងនៅឃុំជប់នឹងណា គាត់នៅខេត្តស្វាយរៀងឯណោះ ឪពុកម្តាយរបស់គាត់បានវែកគាត់មករស់នៅឃុំជប់នឹង
ហើយក៏បានរស់នៅនឹងរហូតទៅ។

កៈ ហើយអញ្ចឹង សំរាប់អ្នកមីង តើអ្នកមីងមាននៅចាំឈ្មោះជីដូនជីតាខាងម្តាយរបស់អ្នកមីងទេ?

ខ៖ អត់ចាំទេ មិនដឹងជាឈ្មោះអីទេ ព្រោះអីកើតមកអត់ឃើញទេ។

ក៖ អញ្ចឹងមានន័យថា ពេលដែលអ្នកមីងកើតមកជីដូនជីតាខាងម្ដាយអត់ដែលឃើញផង គាត់ស្លាប់អត់ហើយអ្នកមីង។ ហើយអញ្ចឹង តើអ្នកមីងមាននៅចាំឈ្មោះជីដូនជីតាខាងឪពុករបស់អ្នកមីងទេ?

ខ៖ មិនដឹងជាឈ្មោះអីទេ ខ្ញុំអត់ចាំទេ។

ក៖ ហើយអញ្ចឹង ពេលដែលអ្នកមីងកើតមកក៏អត់ធ្លាប់ឃើញដែរ?

ខ៖ អត់ឃើញ កើតឡើងមិនឃើញតែម្ដង។

ក៖ អូ! អញ្ចឹងមានន័យថា ជីដូនជីតាខាងម្ដាយរបស់អ្នកមីងក៏មិនដែលឃើញ ហើយជីដូនជីតាខាងឪពុករបស់អ្នកមីងក៏មិនដែលឃើញដែរ។ ហើយអញ្ចឹងសំរាប់ក្រុមគ្រួសាររបស់អ្នកមីងបានរស់នៅខេត្តនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ កើតមករស់នៅនឹងតែម្ដង ខ្ញុំកើតមករស់នៅនឹងរហូតតែម្ដង។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងមានសាច់ញាតិដែលរស់នៅក្រៅប្រទេសខ្មែរទេ អ្នកមីង?

ខ៖ អត់មានទេ។

ក៖ មានតែនៅក្នុងភូមិនឹងតែម្ដង! ហើយអញ្ចឹតសំរាប់ស្វាមីរបស់អ្នកមីង តើគាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខ៖ ស្វាមីរបស់ខ្ញុំគាត់ឈ្មោះ ឆាត់ ឈឿត។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់ក្នុងឆ្នាំណាដែរ អ្នកមីង?

ខ៖ ខ្ញុំរៀបអាពាហ៍ពិពាហ៍ជាមួយគាត់ក្នុងឆ្នាំមួយពាន់ប្រាំបួនរយប៉ែតសិបមួយ។

ក៖ អូ! ឆ្នាំមួយពាន់ប្រាំបួនរយប៉ែតសិបមួយ! ហើយអញ្ចឹងមកដល់សព្វថ្ងៃនេះ តើអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់បានប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ ដឹងប៉ុន្មានឆ្នាំទេ សាម សែសិបឆ្នាំហើយ ព្រោះអីយូរហើយតាំងពីឆ្នាំប៉ែតមួយមកដល់ឥលូវ។

ក៖ សាម សែសិបឆ្នាំហើយអ្នកមីង! ហើយអញ្ចឹងពេលដែលរៀបអាពាហ៍ពិពាហ៍នឹង តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ ពេលអាពាហ៍ពិពាហ៍នឹងខ្ញុំអាយុម្ភៃប្រាំឆ្នាំ។

កៈ អ្នកមីងមានអាយុម្ភៃប្រាំឆ្នាំ! ហើយអញ្ចឹង តើអ្នកមីងបានរៀបអាពាហ៍ពិពាហ៍នៅកន្លែងណាដែរ អ្នកមីង?

ខៈ ខ្ញុំរៀបអាពាហ៍ពិពាហ៍នៅភូមិយើងនឹង។

កៈ អ្នកមីងរៀបអាពាហ៍ពិពាហ៍នៅភូមិពោនយើងនឹងហ៎!
ហើយអញ្ចឹងសំរាប់អាពាហ៍ពិពាហ៍នឹងរៀបចំឡើងដោយឪពុករបស់អ្នកមីង
ឬមួយរៀបចំឡើងដោយនរណាគេដែរ អ្នកមីង?

ខៈ ឪពុកម្ដាយគាត់ជាអ្នករៀបចំអោយ។

កៈ ហើយអញ្ចឹងសំរាប់អាពាហ៍ពិពាហ៍នឹងមានថ្លៃជំនួនទេ អ្នកមីង?

ខៈ កាលជំនាន់នឹងទើបតែបែបពីពលពតភ្លាមគ្មានជំនួនទេ។

កៈ អូ! ជំនាន់នឹងទើបតែបែកពីពួកពលពត អត់ទាន់មានជំនួនមានអីដូចយើងឥលូវនេះទេ។
ហើយអញ្ចឹង អ្នកមីងបានជួបស្វាមីរបស់អ្នកមីងលើកដំបូននៅពេលណាដែរ អ្នកមីង?

ខៈ ជួបនៅឆ្នាំប៉ែតមួយនឹងគាត់ឃើញហើយគាត់ក៏មកសួរនាំយើងទៅ។

កៈ ហើយគាត់មកជួបជាមួយអ្នកមីងនៅកន្លែងណាដែរ អ្នកមីង?

ខៈ គាត់ជួបយើងនៅនឹង។

កៈ អូ! គាត់ឃើញអ្នកមីងនៅផ្ទះនឹង!
ហើយអញ្ចឹងសំរាប់អាពាហ៍ពិពាហ៍របស់អ្នកមីងមានកូនចំនួនប៉ុន្មាននាក់ដែរ អ្នកមីង?

ខៈ មានកូនចំនួនម្នាក់។

កៈ ហើយអញ្ចឹង តើជាកូនប្រុស ឬមួយកូនស្រីដែរ អ្នកមីង?

ខៈ កូនស្រី។

កៈ ហើយអញ្ចឹងសំរាប់កូនស្រីរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខៈ កូនស្រីរបស់ខ្ញុំគាត់ឈ្មោះ ឆាត់ គុន្ធី។

កៈ ហើយអញ្ចឹងសំរាប់កូនស្រីរបស់អ្នកមីងសព្វថ្ងៃនេះ តើគាត់មានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខៈ កូនស្រីរបស់ខ្ញុំគាត់អាយុសាមសិបពីរឆ្នាំហើយ។

កៈ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ តើអ្នកមីងមានចៅហើយឬនៅទេ អ្នកមីង?

ខៈ សព្វថ្ងៃនេះខ្ញុំមានចៅបីនាក់ហើយ។

កៈ ហើយអញ្ចឹង តើអ្នកមីងអាចជួយរាប់ឈ្មោះចៅរបស់អ្នកមីងទាំងបីនាក់បានទេ អ្នកមីង?

ខៈ បងគេបង្អស់ឈ្មោះស្រី ធីតា ហើយទីឈ្មោះខន សុជាតា ហើយទីបីឈ្មោះខន លីម៉េង។

កៈ ហើយអញ្ចឹងសំរាប់អ្នកមីងធ្លាប់មានអនុស្សាវរីយ៍អ្វីល្អៗជាមួយកូនចៅទេ អ្នកមីង?

ខៈ អនុស្សាវរីយ៍ជាមួយកូនចៅល្អរហូតនឹង ព្រោះស្រឡាញ់កូនស្រឡាញ់ចៅ។

កៈ ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងចេះអាន និងសរសេរអក្សរខ្មែរទេ អ្នកមីង?

ខៈ អត់ចេះផង។

កៈ ហើយអញ្ចឹង តើអ្នកមីងចេះនិយាយភាសាផ្សេងក្រៅពីភាសាខ្មែរទេ អ្នកមីង?

ខៈ អត់ចេះអីសោះ ចេះតែខ្មែមួយមុខនឹងទេ។

កៈ ហើយអញ្ចឹង តើអ្នកមីងអត់ដែលបានចូលរៀនសោះតែម្តង ឬមួយអ្នកមីងបានចូលរៀនខ្លះដែរ?

ខៈ បានចូលរៀនខ្លះដែរប៉ុន្តែអត់ចេះ អត់ចាំព្រោះអីយូរហើយ។

កៈ ហើយអញ្ចឹងកាលដែលអ្នកមីងបានរៀននឹង តើអ្នកមីងបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរ អ្នកមីង?

ខៈ ខ្ញុំបានរៀនដល់ថ្នាក់ទីបីជំនាន់ពីដើមយើងនឹង។

កៈ ហើយអញ្ចឹង កាលដែលអ្នកមីងបានរៀននឹង តើអ្នកមីងបានរៀននៅសាលាណាដែរ អ្នកមីង?

ខៈ ខ្ញុំរៀននៅសាលាវាលកណ្តៀងយើងនឹង។

កៈ អូ! សាលាវាលកណ្តៀងនៅឃុំជប់យើងនឹងហ៎! ហើយអញ្ចឹងសំរាប់អ្នកមីង
តើអ្នកមីងមានមិត្តភក្តិជិតស្និតដែលធំធាត់មកជាមួយគ្នានៅភូមិនឹងទេ អ្នកមីង?

ខៈ គ្មានទេខ្ញុំមិត្តភក្តិអត់មានទេ រាប់អានមាន។

កៈ រាប់អានមានតែបើមិត្តភក្តិជិតស្និតអត់មានទេ។
ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះអ្នកមីងមានធ្វើស្រែចំការទេ អ្នកមីង?

ខៈ ខ្ញុំអត់មានស្រែចំការធ្វើនឹងគេផង មានតែរបរប្តីឡើងត្នោតនឹង។

កៈ ហើយអញ្ចឹង សព្វថ្ងៃនេះតើអ្នកមីងធ្វើការងារអ្វីដែរដើម្បីចិញ្ចឹមជីវិត?

ខៈ មានតែធ្វើស្ករត្នោតនឹង។

កៈ អូ! អ្នកមីងធ្វើស្ករត្នោត។ ហើយអញ្ចឹងសំរាប់អ្នកមីងតាំងពីក្មេងរហូតមកដល់ពេលនេះ
តើអ្នកមីងគិតថាជីវិតរបស់អ្នកមីងមានការផ្លាស់ប្តូរទេ?

ខ៖ ផ្លាស់ប្តូរពិបាកនឹងនឿយហាត់រហូតនឹងការងាររកស៊ី។

ក៖ ហើយអញ្ចឹងសំរាប់ម្ហូបវិញ តើអ្នកមីងចូលចិត្តហូបម្ហូបអ្វីជាងគេដែរ អ្នកមីង?

ខ៖ ខ្ញុំចូលចិត្តហូប សម្លរម្ជូរ ប្រហើរ កកូរ។

ក៖ ហើយអញ្ចឹងសំរាប់ល្បែងប្រជាប្រិយខ្មែរយើងដូចជា បោះឈូង បោះអង្គញ់ ទាញព្រ័ត្រ តើអ្នកមីងមានចូលចិត្តលេងល្បែងអីទេ តាំងពីក្មេងមក?

ខ៖ អត់ដែលចូលចិត្តលេងអីទេ ខ្ញុំអត់ចេះលេងល្បែងអីនឹងគេទេ។

ក៖ ហើយអញ្ចឹងសំរាប់បទចម្រៀងវិញ តើអ្នកមីងចូលចិត្តស្តាប់បទចម្រៀងអីតាំងពីតូចរហូតមកដល់ពេលនេះ?

ខ៖ ចូលចិត្តបទរស់ សេរីសុទ្ធា ស៊ីន ស៊ីសាមុត។

ក៖ អូ! អញ្ចឹងបទចម្រៀងពីជំនាន់ដើម។ ហើយអញ្ចឹង តើមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ្នកមីងដែលគាត់ចេះលេងឧបករណ៍ភ្លេងដែរឬទេ អ្នកមីង?

ខ៖ អត់មាន អត់មាននរណាចេះផង។

ក៖ ហើយអញ្ចឹងផ្ទះរបស់អ្នកមីងមានលក្ខណៈដូចម្តេចដែរ ផ្ទះដែលអ្នកមីងបាននៅកាលនៅតូចៗ?

ខ៖ ផ្ទះនៅតូចៗផ្ទះតូចជញ្ជាំងឫស្សីដែលឪពុកម្តាយអ្នកធ្វើ។

ក៖ ហើយអញ្ចឹង តើផ្ទះនឹងនរណាគេជាអ្នកធ្វើដែរ អ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំគាត់ជាអ្នកធ្វើ។

ក៖ អូ! ឪពុករបស់អ្នកមីងគាត់ជាអ្នកធ្វើដោយខ្លួនឯង។ ហើយអញ្ចឹង តើឪពុកម្តាយរបស់អ្នកមីងបានសំភារៈយកមកធ្វើផ្ទះមួយនឹងមកពីណាដែរ អ្នកមីង?

ខ៖ គាត់រកស៊ីបន្តិចបន្តួច គាត់រត់ម៉ូតូទៅរកលុយមកនឹងសន្សំលុយទិញធ្វើផ្ទះនឹងទៅ។

ក៖ ហើយអញ្ចឹងសំរាប់ផ្ទះនឹងធ្វើឡើងដោយសំភារៈអ្វីខ្លះដែរ អ្នកមីង?

ខ៖ មានដើមត្នោត ហើយនឹងកូនឈើយើងនឹងទៅ។

ក៖ ហើយអញ្ចឹងផ្ទះនឹងប្រក់ដំបូលអ្វីដែរ អ្នកមីង?

ខ៖ ដំបូលប្រក់ស័ង្កសី។

កៈ ហើយអញ្ចឹងសំរាប់ផ្ទះមួយនឹង
តើនរណាជាអ្នកបង្រៀនអោយឪពុករបស់អ្នកមីងអោយធ្វើផ្ទះមួយនឹងដែរ អ្នកមីង?

ខៈ ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំកើតមកធំបន្តិចទៅឃើញផ្ទះនឹងគាត់ធ្វើបានអោយនៅ។

កៈ ហើយអញ្ចឹងអ្នកមីងមានជំនាញដែលបន្តវេនពីក្រុមគ្រួសារដូចជា វេញវល្លិ៍ផ្តៅ
ឬក៏ជំនាញធ្វើស្ករត្នោតអីទេ អ្នកមីង?

ខៈ អត់ ខ្ញុំជំនាញតែធ្វើស្ករត្នោតនឹង។

កៈ ហើយអញ្ចឹងជំនាញធ្វើស្ករត្នោតនឹងឪពុកម្តាយរបស់អ្នកមីងគាត់ជាអ្នកបង្រៀន
ឬមួយនរណាគេជាអ្នកបង្រៀនដែរ អ្នកមីង?

ខៈ ប្តីរបស់ខ្ញុំគាត់ជាអ្នកបង្រៀនអោយធ្វើ។

កៈ ហើយអញ្ចឹងសំរាប់ជំនាន់សង្គ្រាម តើអ្នកមីងរស់នៅកន្លែងណាដែរ អ្នកមីង?

ខៈ ជំនាន់សង្គ្រាមគេអោយខ្ញុំទៅនៅក្រុងភ្នំពេញ។

កៈ ហើយអញ្ចឹងកាលនឹងគេអោយអ្នកមីងធ្វើអ្វីដែរ អ្នកមីង?

ខៈ គេអោយទៅធ្វើការក្នុងរោងចក្រចំការកៅស៊ូនៅភ្នំពេញ។

កៈ អូ! គេអោយធ្វើការរោងចក្រចំការកៅស៊ូ។ ហើយអញ្ចឹង
តើជីវិតនៅក្នុងសម័យសង្គ្រាមយ៉ាងម៉េចដែរ អ្នកមីង?

ខៈ វាពិបាកនឹង យើងហូបតែបបរវេទនាណាស់វាមិនដែលបានស្រួលទេ។

កៈ ហើយអញ្ចឹង ក្នុងសម័យនឹងខាងពលពតគេមានធ្វើបាបអីទេ អ្នកមីង?

ខៈ គេធ្វើបាបអោយយើងហូបបបរមួយវែកពីរវែកនឹងទៅ។

កៈ ហូបមិនគ្រប់គ្រាន់! ហើយអញ្ចឹង តើអ្នកមីងមានពេលដែលលំបាកជាងគេនៅក្នុងជីវិតទេ
អ្នកមីង?

ខៈ មានពេលយើងពិបាកពេលយើងអត់មានស្រែធ្វើទិញអង្ករហូបចឹងពិបាក។

កៈ ហើយអញ្ចឹងពេលណាដែលពិបាកជាងគេបំផុត?

ខៈ ពេលយើងចាស់។

កៈ នឹងពិបាកជាងគេ! ហើយអញ្ចឹង អ្នកមីងមានបទពិសោធន៍ណាល្អៗនៅក្នុងជីវិតទេ
ដូចជារៀបការកូន ឬក៏បុណ្យទានអី មានទេ អ្នកមីង?

ខ៖ រៀបការកូន បុណ្យទាន សពម្ដាយអីនឹងមាន។

ក៖ ហើយអញ្ចឹង នៅពេលមានកម្មវិធីនឹងម្ដងៗ តើអ្នកមីងមានអារម្មណ៍យ៉ាងដូចម្ដេចដែរ អ្នកមីង?

ខ៖ អារម្មណ៍ដូចថាពិបាក
ពេលម្ដាយស្លាប់យើងធ្វើបុណ្យយើងពិបាកទៅណាគ្មានសប្បាយចិត្តប៉ុន្មានទេ វាសប្បាយខ្លះទៅ វាកើតទុក្ខខ្លះទៅ។

ក៖ ហើយអញ្ចឹងសំរាប់ចុងក្រោយបើសិនជាអ្នកមីងចង់ផ្ដាំផ្ញើរទៅកូនចៅជំនាន់ក្រោយ
តើអ្នកមីងចង់ផ្ដាំផ្ញើរអ្វីខ្លះដែរ អ្នកមីង?

ខ៖ ផ្ដាំផ្ញើរអោយកូនចៅប្រឹងប្រែងរកស៊ីទៅកុំអោយពិបាកដូចម្ដាយ
អោយប្រឹងរកស៊ីធូរធារកុំអោយពិបាកដូចឪពុកម្ដាយ។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីងបើសិនជាអ្នកមីងចង់អោយកូនចៅជៀសវាង
តើអ្នកមីងចង់អោយគាត់ជៀសវាងពីអ្វីខ្លះដែរ អ្នកមីង?

ខ៖ ចង់អោយពួកគាត់ជៀសវាងពីការផឹកស៊ី ហើយនឹងគ្រឿងញៀងគ្រឿងអីនឹង
ជៀសវាងកុំអោយប្រព្រឹត្តរបស់អស់អញ្ចឹង។

ក៖ ហើយអញ្ចឹងសំរាប់កូនចៅរបស់អ្នកមីងរាល់ថ្ងៃនេះគាត់ធ្វើការងារអ្វីដែរ អ្នកមីង?

ខ៖ កូនប្រសាររបស់ខ្ញុំគាត់ធ្វើការនៅកន្លែងអេតចាយ
ហើយកូនបង្កើតនឹងគាត់នៅមើលកូននៅនឹងផ្ទះ។

ក៖ ហើយអញ្ចឹងសំរាប់កន្លែងអេតចាយនឹងគេអោយកំរៃគាត់យ៉ាងដូចម្ដេចដែរ អ្នកមីង?

ខ៖ មួយថ្ងៃគេអោយពីរម៉ឺនប្រាំពាន់។

ក៖ ហើយអញ្ចឹង រាល់ថ្ងៃនៅពេលយប់កូនប្រសាររបស់អ្នកមីងគាត់មកផ្ទះវិញ?

ខ៖ ម៉ោងប្រាំល្ងាចគាត់មកផ្ទះហើយ។

ក៖ ហើយអញ្ចឹង តើចៅរបស់អ្នកមីងទាំងបីនាក់នឹងរស់នៅនឹងទាំងអស់គាត់មែនទេ?

ខ៖ នៅនឹងទាំងអស់គ្នានឹង។

ក៖ ហើយអញ្ចឹងសំរាប់ខ្ញុំចុងក្រោយនឹង
ខ្ញុំសូមអរគុណច្រើនហើយអ្នកមីងសំរាប់ពេលវេលាដែលអ្នកមីងបានអនុញ្ញាតិអោយខ្ញុំសម្ភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីង ហើយចុងក្រោយខ្ញុំសូមជូនពរអ្នកមីង សូមអោយអ្នកមីងមានសុខភាពល្អ មានកំលាំងមាំមួន មានប្រាជ្ញាវាងវៃ
ហើយសូមជូនពរដល់កូនចៅរបស់អ្នកមីងសូមអោយពួកគាត់មានសុខភាពល្អផងដែរ
ហើយមានប្រាជ្ញាវាងវៃ

ហើយជូនពរអោយកូនរបស់អ្នកមីងគាត់បានជោគជ័យគ្រប់មុខរបរដែលគាត់រកស៊ី
ដើម្បីកូនចៅអ្នកមីងគាត់បន្តរស់នៅហើយរីកចំរើនតទៅមុខទៀត
ហើយសូមជូនពរអោយកូនចៅរបស់អ្នកមីងជៀសផុតពី ជម្ងឺទាំងឡាយដើម្បីគាត់មានសុខភាពល្អ
ហើយគាត់អាចជួយអ្នកមីងលើជីវភាពខ្លះៗទៀត។